# តើស្ថានភាពផ្នែកអន្តោប្រវេសន៍របស់ខ្ញុំគឺជាអ្វី?

នៅពេលអ្នកបានទទួល **បង្កាន់ដៃ** ឬ**ការលើកលែងថ្លៃសេវា** នៅក្នុងប្រអប់សំបុត្រ លោកអ្នកអាចចាប់ផ្តើមពិនិត្យមើលស្ថានភាពផ្នែកអន្តោប្រវេសន៍របស់អ្នកបានតាមរយៈអ៊ីនធឺណិត ឬតាមទូរស័ព្ទ។ ជាទូទៅ នេះគឺជាសំបុត្រទីពីរដែលអ្នកនឹងទទួលពី USCIS (សំបុត្រលើកទីមួយគឺជាសេចក្តីជូនដំណឹង អំពីការចូលគណនី តែគ្មានព័ត៌មានអំពីស្ថានភាពករណី និងមិនតម្រូវការឱ្យមានសកម្មភាពណាមួយទេ)។ ជាធម្មតាអ្នកនឹងទទួលបានបង្កាន់ដៃ ឬការលើកលែងថ្លៃសេវា 4 ទៅ 6 សប្តាហ៍ក្រោយពីការដាក់បញ្ជូនពាក្យស្នើសុំរបស់អ្នក។ សូមរក្សាទុកការជូនដំណឹងនេះដើម្បីបន្តការពិនិត្យស្ថានភាពករណីរបស់អ្នក។ *សូមចងចាំថាវាជារឿងធម្មតាទេដែលអ្នកត្រូវរង់ចាំ ៣ទៅ៤ខែចន្លោះរវាងការណាត់ជួបនីមួយៗ។*

## *សេចក្តីណែនាំសម្រាប់ការពិនិត្យស្ថានភាពករណីរបស់តាមរយៈអ៊ីនធឺណិតៈ*

1. ពិនិត្យមើលបង្កាន់ដៃ ឬការលើកលែងថ្លៃសេវារបស់អ្នក (សូមមើលឧទាហរណ៍នៅខាងក្រោម) ហើយស្វែងរក **លេខបង្កាន់ដៃ** ឬ **លេខពាក្យស្នើសុំ** ដែលស្ថិតនៅ ខាងលើផ្នែកខាងឆ្វេង។ ជាទូទៅ វាចាប់ផ្តើមជាដោយ "NBC" ឬ "IOE" ។


Department of Homeland Security
U.S. Citizenship and Immigration Services
Form I-797C, Notice of Action

THIS NOTICE DOES NOT GRANT ANY IMMIGRATION STATUS OR BENEFIT.

Receipt | NOTICE DATE
CASE TYPE: N-400, Application for Naturalization | USCIS A#
RECEIPT NUMBER: IOE09046 | RECEIVED DATE | PRIORITY DATE | PAGE: 1 of 1
APPLICANT NAME AND MAILING ADDRESS | PAYMENT INFORMATION:


Department of Homeland Security
U.S. Citizenship and Immigration Services
Form I-797C, Notice of Action

THIS NOTICE DOES NOT GRANT ANY IMMIGRATION STATUS OR BENEFIT.

Fee Waiver Approved | NOTICE DATE
CASE TYPE: N-400, Application for Naturalization | USCIS A#: A205676
RECEIPT NUMBER: IOE090467 | RECEIVED DATE | PRIORITY DATE | PAGE: 1 of 1
APPLICANT NAME AND MAILING ADDRESS | PAYMENT INFORMATION:

2. ចូលទៅកាន់ [www.uscis.gov](http://www.uscis.gov) ហើយចុច "ពិនិត្យមើលស្ថានភាពករណីរបស់អ្នក"។ សូមមើលឧទាហរណ៍ខាងក្រោម។




3. វានឹងនាំអ្នកទៅទំព័រថ្មី ដែលអ្នកអាចដាក់បញ្ចូលលេខពាក្យស្នើសុំ ឬលេខបង្កាន់ដៃរបស់អ្នកចូលក្នុងប្រអប់។




4. នៅពេលអ្នកចុច "ពិនិត្យស្ថានភាព" អ្នកនឹងត្រូវនាំទៅទំព័រដែលនឹងប្រាប់អ្នកអំពីស្ថានភាពផ្នែកអន្តោប្រវេសន៍របស់អ្នក។



**ចំណាំ៖** វាមិនផ្តល់កាលបរិច្ឆេទ និងពេលវេលាច្បាស់លាស់នៃការណាត់ជួបរបស់អ្នកឡើយ។ វាគ្រាន់តែប្រាប់អ្នកថាការណាត់ជួបរបស់អ្នកត្រូវបានកំណត់ពេល ហើយសំបុត្រជូនដំណឹងត្រូវបានផ្ញើទៅកាន់លោកអ្នក។ ព័ត៌មានកាលបរិច្ឆេទ និងពេលវេលាការណាត់ជួបទាំងអស់នឹងត្រូវបានផ្ញើតាមរយៈសេចក្តីប្រកាស។ សូមប្រាកដថា ពិនិត្យមើលប្រអប់សំបុត្ររបស់អ្នកឱ្យបានទៀងទាត់ ។ ស្ថានភាពករណីរបស់អ្នកនៅលើបណ្តាញអ៊ីនធឺណិតមិនមែនជានិច្ច
កាលត្រូវបានគេកែប្រែទាន់ពេលនោះទេហើយវាប្រហែលមិនតំណាងស្ថានភាពជាក់ស្តែងនៃករណីរបស់លោកអ្នកឡើយ ។

### *សេចក្តីណែនាំសម្រាប់ការពិនិត្យមើលស្ថានភាពករណីរបស់អ្នកតាមទូរស័ព្ទរយៈ៖*

1. ទូរស័ព្ទទៅលេខ 1-800-375-5283
2. ចុចលេខ 1 ដើម្បីបន្តជាភាសាអង់គ្លេស ចុចលេខ 2 សម្រាប់ភាសាអេស្ប៉ាញ
3. ចុចលេខ 1 សម្រាប់សេវាអន្តោប្រវេសន៍
4. ចុចលេខ 1 ដើម្បីពិនិត្យមើលស្ថានភាពពាក្យស្នើសុំ
5. ចុចលេខ 1 ប្រសិនបើអ្នកដឹងលេខបង្កាន់ដៃរបស់អ្នក
6. បញ្ចូលលេខកូដ 13 តួរបស់អ្នក (ជាទូទៅចាប់ផ្តើមជាដោយ NBC* ឬ IOE)
7. ចុចលេខ 1 ដើម្បីបញ្ជាក់លេខដែលអ្នកបានវាយបញ្ចូល
8. ស្តាប់អំពីស្ថានភាពករណីនាពេលបច្ចុប្បន្នរបស់លោកអ្នក។